

# ការចាក់ថ្នាំបង្ការជំងឺ COVID-19 នៅតាមផ្ទះ គឺអាចរកបានសម្រាប់ពលរដ្ឋនៅក្នុងខោនធី LA ដែលមិនអាចធ្វើដំណើរចេញពីផ្ទះបាន

## តើខ្ញុំមានសិទ្ធិអាចចូលរួមបាន ដែរឬទេ?

អ្នកមានសិទ្ធិចូលរួមបាន ប្រសិនបើអ្នកមានការពិបាកក្នុងការធ្វើដំណើរចេញពីផ្ទះរបស់អ្នកដោយខ្លួនឯងហើយដោយសុវត្ថិភាព ដើម្បីទទួលចាក់ថ្នាំបង្ការប្រឆាំងនឹងជំងឺ COVID-19 នោះ។

## ការចុះឈ្មោះ៖

ការបញ្ជូនឈ្មោះដោយខ្លួនឯង ហើយនិងការបញ្ជូនឈ្មោះពីអង្គភាព ទីភ្នាក់ងារ អ្នកផ្តល់សេវាកម្មផ្នែកថែទាំសុខភាព អ្នកមើលថែទាំ សមាជិកក្រុមគ្រួសារ និងមនុស្សជាទីស្រឡាញ់ទាំងឡាយ សុទ្ធតែអាចទទួលបានទាំងអស់!

- អ្នកអាចស្នើសុំការចាក់ថ្នាំបង្ការនៅតាមផ្ទះបាន ដោយបំពេញបែបបទតាមអនឡាញមួយ (សូមមើលផ្នែកខាងក្រោម)។

**https://redcap.link/vaxathome**

**សូមដាក់កាមេរ៉ាទូរស័ព្ទរបស់អ្នកនៅលើប្រអប់ការ៉េនេះ ដើម្បីចូលទៅកាន់គេហទំព័រ**

- អ្នកក៏អាចទូរស័ព្ទទៅកាន់លេខ 1-833-540-0473 (បម្រើសេវាកម្មចាប់ពីម៉ោង 8 ព្រឹក ដល់ម៉ោង 8:00 យប់ 7 ថ្ងៃក្នុងមួយសប្តាហ៍) ឬទូរស័ព្ទទៅកាន់លេខ 2-1-1 ដើម្បីស្នើសុំការចាក់ថ្នាំបង្ការនៅតាមផ្ទះបាន តាមរយៈទូរស័ព្ទផងដែរ។ មានផ្តល់ជូនសេវាកម្មជាច្រើនភាសា។

## ទទួលចាក់ថ្នាំបង្ការ ដើម្បីបន្តមានប្រព័ន្ធការពារ!

មានការណែនាំឱ្យមនុស្សគ្រប់រូបដែលមានអាយុចាប់ពី 6 ខែឡើងទៅ ទទួលចាក់ថ្នាំបង្ការជំងឺ COVID-19 ដែលបានធ្វើឱ្យថ្មីឡើងវិញសម្រាប់ឆ្នាំ 2023-2024 (updated 2023-2024 COVID-19 vaccine)! មនុស្សពេញវ័យដែលមានអាយុចាប់ពី 65 ឆ្នាំឡើងទៅគួរតែទទួលចាក់ថ្នាំបង្ការជំងឺ COVID-19 ដែលបានធ្វើឱ្យថ្មីឡើងវិញចំនួនមួយដូសបន្ថែមទៀត ក្នុងរយៈពេលយ៉ាងហោចណាស់ 4 ខែ បន្ទាប់ពីការចាក់ដូសពីពេលមុនរបស់ពួកគេ។

ប្រសិនបើអ្នកមានសំណួរផ្សេងៗអំពីការចាក់ថ្នាំបង្ការនៅតាមផ្ទះ ឬអំពីថ្នាំបង្ការជំងឺ COVID-19 ជាទូទៅ សូមទូរស័ព្ទទៅកាន់នាយកដ្ឋានសុខភាពសាធារណៈ (Public Health) តាមរយៈលេខ 1-833-540-0473 ឬក៏ចូលទៅកាន់គេហទំព័ររបស់យើងខ្ញុំតាមរយៈ: VaccinateLACounty.com ឬ ph.lacounty.gov/VaxAtHome។



County of Los Angeles Public Health